00829456

E216/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 31 / 07 / 2012
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

**សាធារណៈ / Public**

ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីនៃសំណុំរឿង ០០២

**ពី:** និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ចម្លើយតបទៅនឹងសំណើដែលពុំទាន់បានដោះស្រាយក្នុងឯកសារ E216

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយពីសហព្រះរាជអាជ្ញា ដែលស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតប្រគល់ឯកសារមួយដែលសាក្សីដែលមានរហស្សនាម TCW-694 បានប្រគល់ទៅសហចៅក្រមស៊ើបអង្កេត ក្នុងអំឡុងកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត កាលពីឆ្នាំ ២០០៩ និងដើម្បីដាក់ឯកសារនេះទៅក្នុងសំណុំរឿង (ឯកសារ E216)។ ឯកសារនេះគឺជានិក្ខេបបទ ឬសំណេរដែលពុំទាន់បានបោះពុម្ពផ្សាយ ដែលត្រូវបានសរសេរដោយសាក្សីដែលមានរហស្សនាម TCW-694 និងត្រូវបានសហចៅក្រមស៊ើបអង្កេតនិយាយយោងដោយអន្លើក្នុងការសួរសំណួរដល់សាក្សីរូបនេះ (ឯកសារ E3/377)។ សហចៅក្រមស៊ើបអង្កេតបានសម្រេចពុំដាក់ឯកសារនេះនៅក្នុងសំណុំរឿងទាំងស្រុងឡើយ (ឯកសារ E216/2) ប៉ុន្តែសម្រង់ខ្លះនៃឯកសារនេះត្រូវបានដាក់នៅក្នុងសំណុំរឿង និងដាក់នៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E3/40)។

២.　ដើម្បីវាយតម្លៃអំពីខ្លឹមសារនៃសំណើរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានស្នើសហចៅក្រមស៊ើបអង្កេតឲ្យប្រគល់ឯកសារនេះ (ឯកសារ E216/1)។ សហចៅក្រមស៊ើបអង្កេតជាតិបានយល់ព្រមតាមសំណើនេះ កាលពីថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ (ឯកសារ E216/2)។ និក្ខេបបទនេះមានចំនួនប្រហែល ២៨៤ ទំព័រ និងមានតែជាភាសាបារាំងប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ខ្លួនបានធ្វើសំណើសុំដើម្បីប្រើប្រាស់និក្ខេបបទនេះសម្រាប់សាកសួរសាក្សី នៅពេលគាត់ផ្តល់សក្ខីកម្មនៅក្នុងសវនាការ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សំណើសុំនេះត្រូវបានធ្វើឡើងដើម្បីដាក់ឯកសារនៅក្នុងសំណុំរឿងផង និងដើម្បីដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះផង។

៣.　បើទោះបីជាអង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ថា ឯកសារទាំងឡាយដែលសហចៅក្រមស៊ើបអង្កេតបានយកមកប្រើប្រាស់ក្នុងអំឡុងស្តាប់យកចម្លើយសាក្សី គឺជាផ្នែកមួយនៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីនោះ ហើយនិងអាចត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននេះ (ប្រតិចារឹក, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២, ទំព័រ ៥) ក៏ដោយ ក៏អង្គជំនុំជម្រះធ្លាប់បានគូសបញ្ជាក់ថា ឯកសារនានាដែលត្រូវបានបង្ហាញនៅសវនាការគួរគប្បីមានជាបីភាសាផ្លូវការនៅ អ.វ.ត.ក (ឯកសារ E131/1)។ អង្គជំនុំជម្រះអាចផ្តល់ការពន្យារពេលខ្លះដល់ភាគីពាក់ព័ន្ធនឹងបញ្ហានេះ នៅពេលឯកសារណាមួយដែលត្រូវប្រើប្រាស់ដើម្បីធ្វើជាមូលដ្ឋាននៃការសួរសំណួរសាក្សីមានជាភាសាដែលសាក្សីអាចយល់បាន ហើយបន្ទុកការងារនៅអង្គភាពបកប្រែភាសាពុំអនុញ្ញាតឲ្យអង្គភាពនេះអាចបកប្រែបានទាន់ពេលវេលា ឬផ្នែកពាក់ព័ន្ធនៃ ឯកសារដែលនឹងត្រូវប្រើប្រាស់នោះគឺជាផ្នែកសង្ខេបខ្លី និងអាចត្រូវបានបកប្រែដោយងាយស្រួលនៅ ពេលសវនាការ (ឯកសារ E162)។

៤.　ដោយគិតទៅលើកម្រាស់នៃនិក្ខេបបទនេះ ការបកប្រែជាភាសាអង់គ្លេស និងភាសាខ្មែរនឹងពុំអាចត្រូវបានធ្វើទាន់ពេលវេលា មុនការបង្ហាញខ្លួនរបស់សាក្សីដែលមានរហស្សនាម TCW-694 បានឡើយ។ ផ្នែកខ្លះ នៃនិក្ខេបបទនេះបានស្ថិតនៅក្នុងសំណុំរឿងចាប់តាំងពីថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៧ (ជាភាសា បារាំង) និងថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ (ជាភាសាអង់គ្លេស) ដូច IS៣.៩ ។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយដែលក្នុងនោះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងអំពីនិក្ខេបបទនេះ បានស្ថិតនៅក្នុងសំណុំរឿង ចាប់តាំងពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ (ឯកសារ

D168)។ ការទទួលបានឯកសារនេះពីសហចៅក្រមស៊ើបអង្កេត និងការធានាបាននូវការបកប្រែបានទាន់ពេលវេលា នៅមុនពេលនៃការបង្ហាញខ្លួនតាមការគ្រោងទុករបស់សាក្សីដែលមានរហស្សនាម TCW-694 គឺជាបន្ទុករបស់សហព្រះរាជអាជ្ញា។ ផ្ទុយទៅវិញ បញ្ហានេះទើបតែត្រូវបានជូនដំណឹងមកអង្គជំនុំជម្រះ នៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ តែប៉ុណ្ណោះ។

៥. ក្នុងកាលៈទេសៈបែបនេះ អង្គជំនុំជម្រះបដិសេធសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំដាក់និក្ខេបបទនេះទាំងស្រុងទៅក្នុងសំណុំរឿង។ បើទោះបីជាដូច្នេះក្តី អង្គជំនុំជម្រះបានដាក់ទៅក្នុងសំណុំរឿងនូវឧបសម្ព័ន្ធមួយភ្ជាប់ទៅនឹងអនុស្សរណៈនេះ ដែលជាសម្រង់ខ្លីៗចំនួន ៦ នៃនិក្ខេបបទខាងលើដែលឆ្លើយតបទៅនឹងផ្នែកនានា ដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងការស្តាប់ចម្លើយរបស់ខ្លួន (ឯកសារ E3/377)។ សំណើសុំបកប្រែសម្រង់ខ្លីៗទាំងអស់នេះជាភាសាអង់គ្លេស និងភាសាខ្មែរត្រូវបានស្នើរួចហើយ។ អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យភាគីទាំងអស់ដាក់សម្រង់ទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ និងយោងទៅលើផ្នែកនានានៃឧបសម្ព័ន្ធនេះ នៅពេលសួរសំណួរសាក្សីដែលមានរហស្សនាម TCW-694 ក្នុងករណីដែលផ្នែកទាំងអស់នោះជាផ្នែកសង្ខេបខ្លីៗ ហើយអាចបកប្រែបានដោយងាយស្រួលនៅពេលសវនាការ។